Living the Lotus
Buddhism in Everyday Life
New Year's Issue




# 『ចូរយើងគិតជាថ្មីម្តងទៀត ហើយប្រើគំនិតច្នៃប្រឌិត 』

ព្រះប្រធានរីស្សូកូសេកៃ
ព្រះគ្រូ នីវ៉ាណូ នីជីកុ

## ជម្ងឺឆ្លងរាលដាលកូវីដ១៩បានផ្តល់នូវឱកាសសម្រាប់ឱ្យយើងអាចគិតពីអ្វីដែលមានតម្លៃបំផុតសម្រាប់មនុស្សលោកៗ



សួស្តីឆ្នាំថ្មី។

ឆ្នាំមុនមេរោគកូរ៉ូណាបានឆ្លងរាលដាលហើយជះឥទ្ធិពលយ៉ាងធំទៅលើជីវភាពរស់នៅរាល់ថ្ងៃ។នៅទូទាំងពិភពលោកមនុស្សដែលបានទទួលមរណភាពដោយមេរោគនេះមានចំនួន១លាន៦សែននាក់ ។ខ្ញុំព្រះករុណាអាត្មាភាពមានសេចក្តីសោកស្តាយនិងសូមចូលរួមរំលែកទុក្ខសោកជាមួយនឹងគ្រួសារអ្នករងគ្រោះទាំងនេះពីជម្រៅដួងចិត្ត។

រីហ្សូកូសេកៃរបស់យើងបានបិទព្រះវិហារធំនៅ
តូក្យូព្រមទាំងការិយាល័យផ្សព្វផ្សាយព្រះធម៌ទាំងអស់ទូទាំងប្រទេសព្រមទាំងសកម្មភាពនានាហើយបានពន្យាពេលដើម្បីចាត់វិធានការណ៍ការពារឱ្យបានពេញទំហឹង។

ម្យ៉ាងទៀតជីវភាពរស់នៅរបស់មនុស្សម្នាក់ៗតាំងពីរបៀបធ្វើការ ការអប់រំ ការចិញ្ចឹមកូន ការថែទាំមនុស្សចាស់ការងារផ្ទះជាដើមក៏បានប្រែប្រួលយ៉ាងច្រើនហើយតម្រូវឱ្យមានការឆ្លើយតបទៅនឹងការប្រែប្រួលនោះផងដែរ។

មានមនុស្សជាច្រើនបានបាត់បង់ប្រាក់ចំណូលមួយភាគធំ អ្នកខ្លះទៅបាត់បង់ការងារ អ្នកខ្លះទៀតត្រូវបិទអាជីវកម្ម។ក្នុងខណៈបែបនេះក្នុងនាមជាមិត្តល្អ ជាគណៈសង្ឃ អាត្មាភាពចង់ឱ្យយើងមានសមានចិត្ត សហការគ្នា ជួយគ្នាទៅវិញទៅមកទើបបាន។

ខ្ញុំព្រះករុណាអាត្មាភាពយល់ថាគ្រោះមហន្តរាយកូវីដ១៩

នេះជាឱកាសសម្រាប់ឱ្យមនុស្សសម្លឹងនិងគិតជាថ្មីឡើងវិញថាតើអ្វីទៅដែលសំខាន់ពិតប្រាកដចំពោះមនុស្សនោះ។

កាលពីមុនខ្ញុំព្រះករុណាអាត្មាភាពបានជំរាបម្តងហើយថាអក្សរចិន「省」(shou)នេះមានន័យ

ពីរ។ទី១គឺ កាត់ចេញឬលុបចោល និងទី២គឺ គិតជាថ្មីឡើងវិញពីអ្វីដែលបានធ្វើហើយដូច្នេះជីវភាពនៅក្នុងគ្រោះកូវីដយើងមានឱកាសអាចគិតឃើញថាតើត្រូវកាត់អ្វីចោលហើយតើត្រូវគិតមើលឡើងវិញជាថ្មីពីអ្វីមួយមិនខានឡើយ។



យោលទៅតាមការធ្វើអង្កេតពីយោបល់សាធារណជនមួយដែលចោទជាសំណួរថាតើឥទ្ធិពលនៃកូវីដ១៩ ធ្វើឱ្យមនុស្សម្នាចាប់ផ្តើមទម្លាប់ថ្មីអ្វីមួយនៅក្នុងជីវភាពរស់នៅឬទេ?ចម្លើយ៧៤%គឺកាន់តែស្រឡាញ់គ្រួសារជាងមុន។ផ្ទុយទៅវិញក៏មានករណីនាំឱ្យទំនាស់ក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរទៅៗរហូតដល់មានពាក្យថា《លែងលះគ្នាដោយសារកូវីដ》ទៅទៀត។ក្នុងន័យនេះខ្ញុំព្រះករុណាអាត្មាភាពសូមបង្ហាញ《មុខសញ្ញានៃឆ្នាំ២០២១》ដូចខាងក្រោមនេះ។

ពីឆ្នាំមុន ដោយសារការរាលដាលនៃការឆ្លងជម្ងឺកូ

វីដ រចនាបថនៃការរស់នៅរបស់យើងទាំងអស់គ្នាបានប្រែប្រួលច្រើន ។ យើងសម្ងំនៅក្នុងផ្ទះ មិនចេញក្រៅ,ការងារក៏ធ្វើតាមបណ្តាញអ៊ីនធឺណេតពីផ្ទះហើយចំណោទសួរទៅលើតម្លៃនៃទំនាក់ទំនងក្នុងគ្រួសារក៏ចោទឡើង។

ឆ្នាំនេះជាខួបគម្រប់៨៣ឆ្នាំនៃរីហ្សូកូសេកៃយើង។ដូចតែឆ្នាំមុនដែលអាត្មាភាពគិតថាប្រហែលជាយើងត្រូវឃុំខ្លួនក្នុងផ្ទះបន្តហើយៗឆ្លងកាត់តាមជីវភាពដែលមានជំនឿលើព្រះពុទ្ធសាសនានៃយើងទាំងអស់គ្នា អាត្មាភាពសូមឱ្យគិតពីការ

បណ្តុះបណ្តាលវ័យកុមារនិងយុវជនជាបុត្រដែលកំពុងតែចងក្រងអត្តចរឹតខ្លួនគេដែលជាទំពាំងស្នងឫស្សីត្រូវទ្រទ្រង់សង្គមបន្តវេនពីយើងសូមបំពេញតួនាទីជាស្វាមីភរិយា ជាឪពុកម្តាយនិងតាយាយហើយរិះគិតបែបច្នៃប្រឌិតនិងឱ្យបានហ្មត់ចត់ថាតើត្រូវធ្វើយ៉ាងណាដើម្បីរៀបចំគ្រួសារឱ្យមានសណ្តាប់ធ្នាប់។

《ស្វាមីភរិយា》ដែលអាត្មាភាពនិយាយនេះគឺសំដៅទៅលើគូស្វាមីភរិយាក្មេងៗ,《ឪពុកម្តាយ》គឺសំដៅទៅរកអ្នកមានវ័យច្រើនបន្តិចដែលកំពុងតែធ្វើការងារសស្រាក់សស្រាំ រីឯ《តាយាយ》គឺសំដៅទៅលើមនុស្សចាស់អាយុចំណាស់ដែលមានបទពិសោធន៍ច្រើនក្នុងជីវិតក្នុងន័យថាសូមឱ្យផ្ទេរបទពិសោធន៍ទាំងឡាយទៅកូនទៅចៅទៅកូនប្រសារផងដើម្បីចូលរួមចំណែកក្នុងការបណ្តុះ

បណ្តាលកុមារនិងយុវជនមួយជំនាន់ៗ។

《មុខសញ្ញា》នេះអាត្មាភាពមានឱកាសបានពន្យល់នៅក្នុង《ការប្រជុំថ្នាក់ដឹកនាំ》យើងកាលពីខែ១១ឆ្នាំមុនចំពោះអស់លោកប្រធានព្រះវិហារនានាទូទាំងប្រទេសជប៉ុនហើយ។ពេលនោះខ្ញុំព្រះករុណាអាត្មាភាពបានលើកយកឃ្លាមួយវគ្គពីក្នុងសៀវភៅរបស់ព្រះគ្រូយ៉ាស៊ុអ្វូកា ម៉ាសាហ៊ីរ៉ូដែលនរណាម្នាក់ក៏ស្គាល់ថាជាតារានៃទស្សនវិជ្ជាផ្នែកលោកខាងកើតមកជម្រាបជូនអង្គប្រជុំ។

នៅផ្ទះកូនត្រូវតែគោរពឪពុកហើយត្រូវទទួលការគោរពមកវិញ។គេរៀនសេចក្តីស្រឡាញ់ពីម្តាយ។គោរពគឺគោរពខ្លួនឯងនិងគោរពមនុស្សដទៃ។គោរពគឺបណ្តាលឱ្យចិត្តចង់ទៅជាធំជាងនេះសម្បើមជាងនេះ ពោលគឺធ្វើអោយខ្លួនឯងវិវឌ្ឍទៅមុខ។

បច្ចុប្បន្ននេះគេនិយាយតែពីស្នេហារបស់ម្តាយ ហើយលែងនិយាយពីការគោរពឪពុក។ឪពុកឯណោះក៏គិតតែពីការងារ មិនសូវមានពេលគិតពីគ្រួសារ។ឪពុកគិតថាផ្ទះជាកន្លែងសម្រាកលំហែ មិនរៀបឬកមិនគិតពីឥរិយាបទសមរម្យ មិនរអែងចិត្តនរណា។បើចេះខ្មាសមនុស្សនឹងមានសណ្តាប់ធ្នាប់។ចំពោះមនុស្ស គោលការណ៍សំខាន់ជាងគេគឺ《សេចក្តីគោរព》 និង《ការអៀនខ្មាស》។

កុមារជាអត្ថិភាពស្អាតស្អំ ចូលចិត្តលេងហាក់លោតសើចសប្បាយ។ជាពិសេសកុមារតែងមើលហើយធ្វើតាមអ្វីដែលឪពុកម្តាយធ្វើ។ប្រសិនបើឪពុក

ម្តាយមានចរឹតនិងអកប្បកិរិយាមិនត្រឹមត្រូវ ពោលគឺផ្ទាប់និស្ស័យនឹងអ្វីដែលមិនល្អប្រសើរនឹងអាចមានឥទ្ធិពលទៅលើអនាគតកាលរបស់កូន។ដូច្នេះឪពុកម្តាយតោងតែទាញយកមកវិញនូវ

កតព្វកិច្ចឬតួនាទីជាមាតាបិតា។

ហើយចុងបញ្ចប់ធ្វើម៉េចឱ្យ《ឪពុកទៅជាមុខសញ្ញានៃការគោរពពីកូន។ម្តាយក៏តោងតែនៅជាទឹកន្លែដែលផ្ទុកនូវសេចក្តីស្នេហានិងមេត្តា។ពីព្រោះថាគ្រួសារគឺជាស្រែសម្រាប់ស្ទូងសំណាបកុមារ》។

ទង្វើនេះយើងទាំងឡាយតោងតែខ្ជប់ទុកក្នុងបេះដូងហើយប្រព្រឹត្តជាប្រចាំ។នៅក្នុងវីហ្សូកូសេកៃយើងក៏ដូច្នេះដែរលោកអ្នកខំប្រឹងក្នុងសកម្មភាពផ្សព្វផ្សាយពេកក៏ទៅជាភ្លេចគិតពីគ្រួសារក៏មាន។ពីពេលនេះតទៅមុខសូមគិតថាព្យាយាមធ្វើការផ្សព្វផ្សាយព្រះធម៌ក៏សំខាន់ហើយ      គិតពីគ្រួសារក៏សំខាន់ដែរ។

## តើយើងត្រូវបណ្តុះបណ្តាលនិងគិតគូរពីការបង្កបង្កើតបុគ្គលិកលក្ខណៈនិង អត្តចរិតនៃកុមារតូចៗ កុមារធំ និងយុវជនទាំងឡាយដែលជាអនាគតសរសរទ្រូងនៃសង្គម យ៉ាងដូចម្តេច?

រហូតមកដល់ពេលនេះអាត្មាភាពបានជម្រាបអ្នកទាំងអស់ថាប្រធានបទជាគោលការណ៍របស់ខ្ញុំព្រះករុណាអាត្មាភាពគឺនឹងចំណាយកម្លាំងទាំង ស្រុងក្នុងការបណ្តុះបណ្តាលមនុស្ស។

ហើយជាគ្រឹះសំខាន់ជាងគេគឺការអប់រំនៅក្នុងគ្រួសារ។ការធ្វើឱ្យមានសណ្តាប់ធ្នាប់ល្អនៅក្នុងគ្រួសារនាំឱ្យមានការអប់រំល្អ    ប្រៀនប្រដៅណែនាំមនុស្សឱ្យបានល្អហើយបន្តទៅដល់សិក្សាធិការល្អថែមទៀត។ក្នុងន័យនេះហើយដែលអាត្មាភាពគិតថានឹងបន្តផ្ទាប់ទៅនឹងការបណ្តុះបណ្តាល

មនុស្ស។

ខ្ញុំព្រះករុណាអាត្មាភាពបាននិយាយផងដែរថា៖នៅក្នុងការពិតជាក់ស្តែងដើម្បីឱ្យគ្រួសារមាន

សណ្តាប់ធ្នាប់ល្អតោងតែមានការគោរពបូជាព្រះពុទ្ធរូបដែលមាននៅក្នុងផ្ទះយើងម្នាក់ៗ  និងកិច្ចប្រតិបត្តិ  ៣  គឺពេលព្រឹកត្រូវធ្វើគារវកិច្ចនៅក្នុងគ្រួសារ,នៅពេលគេហៅត្រូវឆ្លើយច្បាស់ៗថាចាសឬបាទ    ។ពេលដោះស្បែកជើងត្រូវតម្រឹមវាជាគូឱ្យបានត្រឹមត្រូវ។ប្រសិនបើមានបាតគ្រឹះត្រឹមត្រូវបែបនេះហើយការអប់រំជាគោលការណ៍របស់មនុស្សគឺបានសម្រេចហើយ។

ម្យ៉ាងទៀតអ្វីដែលសំខាន់បំផុតជាបាតគ្រឹះនៃការអប់រំបុត្រធីតានៅក្នុងផ្ទះ  គឺបញ្ហាថាតើឪពុកម្តាយចាត់ទុកកូនថាជាអ្វី ពោលគឺ《ទស្សនៈទៅលើកុមារជាកូនខ្លួន》។

តាំងពីដើមមកនៅជប៉ុនគេតែងតែគិតថាកូនគឺជាអំណោយពីព្រះជាម្ចាស់។ដូច្នេះគេគោរពកុមារហើយចិញ្ចឹមកុមារក្នុងនាមជាទានពីព្រះ។

ពីមុនអាត្មាធ្លាប់បានអានសៀវភៅរបស់លោកគ្រូចាងហ្វាងដំបូងបង្អស់នៃវិទ្យាល័យយេយវ៉ានៅស្រុកនីង៉ាតា,ខេត្តនីង៉ាតា។លោកគ្រូអូតាជាអ្នកកាន់សាសនាគ្រឹស្ទ។កាលលោកនៅពីក្មេងលោកខ្សោយឧស្សាហ៍ឈឺមានក្មេងដទៃទៀតធ្វើបាបលោក។នៅពេលបែបនេះមាតាលោកក៏លួងលោមលោកថា៖កូនឯងនេះមានសុខភាពខ្សោយ   ដូច្នេះផ្លូវចិត្តក៏ខ្សោយដែរក៏ប៉ុន្តែចាំមើលទៅគង់តែថ្ងៃណាមួយឯងនឹងធំហើយនឹងធ្វើកិច្ចការដែលព្រះជាម្ចាស់លោកដាក់មកឱ្យមកបានយ៉ាងត្រឹមត្រូវ។ម៉ែជឿថាថ្ងៃនោះនឹងចូលមកដល់ដូច្នេះម៉ែគ្មានពិបាកចិត្តអីបន្តិចទេ។នៅពេលដែលកូននៅខ្សោយ កូនយំឱ្យអស់ចិត្តទៅ។

លោកគ្រូអូតាបានរំលឹកពីការឆ្លើយតបទៅនឹងជំនឿជឿជាក់មកលើរូបលោកពីមាតារបស់លោកគឺលោកបានប្តេជ្ញាហើយមិនប្តូរចិត្តតាំងពីលោកចំរើនវ័យពីយុវវ័យទៅ។

មើលទៅមាតាដែលជឿជាក់ថាកូនរបស់ខ្លួនមានការផ្ទុកផ្តាក់កិច្ចការពីព្រះជាម្ចាស់    ហើយគោរពកូនរៀងរហូតមកនេះនាំឱ្យរំភើបចិត្តពន់ពេក

ណាស់។





កូនៗមើលទង្វើម្ដាយឪពុកគ្រប់ដំណើរហើយអនាគតកាលក៏នឹងទៅជាយ៉ាងនោះ។ល្អក៏ត្រាប់តាមអាក្រក់ក៏ត្រាប់តាម។អ្វីដែលឪពុកម្ដាយធ្វើនឹងជះឥទ្ធិពលទៅលើកូនទាំងអស់។

ពីដើមនៅស្រុកចិនមាននិទានពីរឿងរបស់អ្នកនយោបាយម្នាក់ឈ្មោះសៀ អាន (គស 260-420) ។ភរិយាសៀអានដែលជានារីតឹងរ៉ឹងក្នុងការប្រដៃប្រដៅអប់រំកូនបានសួរទៅស្វាមីថា៖ហេតុអ្វីបានជាបងមិនបង្រៀនអីកូនអីចឹង?។សៀអានក៏ឆ្លើយទៅវិញថា៖បងបង្រៀនកូនពីព្រឹកទល់ល្ងាចមួយថ្ងៃ២៤ម៉ោងគ្រាន់តែថាបងមិនប្រើមាត់ឬប្រើដៃបង្រៀនប្រៀនប្រដៅគេទេ បងបង្រៀនគេដោយរាងកាយបងទាំងមូលតែម្ដង។ពោលគឺថាការប្រៀនប្រដៅកូនមិនមែនការនិយាយកោកៗឬប្រើដៃវាយតប់ក្មេងនោះទេ គឺការបង្ហាញគម្រូដល់គេតាមរយៈទង្វើរបស់យើងជាម្ដាយឪពុក។នេះជាគោលការណ៍នៃការអប់រំកុមារ។

មានរឿងផ្សេងទៀតដែលអាត្មាភាពចង់លើកយកមកជម្រាប។នៅជំនាន់ដែលជប៉ុនមានសង្គ្រាមផ្ទៃក្នុងឈ្លោះគ្នាច្បាំងដណ្ដើមអំណាចគ្នាមិនឈប់,មានសាមូរ៉ៃល្បីល្បាញឈ្មោះលោកហូសូកាវ៉ា យូសៃ។នៅពេលដែលលោកចាស់ទៅនៅពេលបុត្រាដែលមានគ្រួសារហើយមកលេងផ្ទះលោកៗសម្រួលឥរិយាបទនិយាយលេងធម្មតា តែនៅពេលដែលចៅៗរបស់លោកមកលេងលោកស្លៀកពាក់ហំហួនប្រកាន់ឥរិយាបទនិងធ្វើមុខមាំជាសាមូរ៉ៃ។នៅពេលដែលគេសួរលោកៗឆ្លើយថា៖ចៅរបស់ខ្ញុំវានឹងទៅជាមនុស្សម្នា។យើងតោងតែទទួលគេដោយសេចក្ដីគោរព។

នៅក្នុងគ្រួសារអាត្មាភាពក៏បែបនេះដែរ។កាលពីកែសូសាម៉ាលោកនៅមានព្រះជន្មនៅឡើយចាប់ពីពេលដែលលោកងើបសូត្រធម៌រហូតដល់ពេលលោកចេញទៅធ្វើការនៅទីស្នាក់ការកណ្ដាល នៅក្នុងជីវភាពរាល់ថ្ងៃលោកមានតារាងចែកពេលវេលាច្បាស់លាស់ត្រឹមត្រូវរបស់លោក។ពួកយើងជាកូនៗជួនកាលទៅមិនទាន់ពេលលោកសូត្រធម៌ តែកែសូសាម៉ាលោកសូត្រតាមពេលកំណត់របស់លោក។នៅពេលដែលឃើញលោកធ្វើបែបនេះយើងជាកូនៗគិតថា លោកពិតជាមានជំនឿពីជម្រៅបេះដូងរបស់លោកមែន។

ពាក្យថាប្រៀនប្រដៅកូន ចិញ្ចឹមកូនតាមពិតទៅគឺជាបញ្ហាគំនិតនិងឥរិយាបទរបស់មាតាបិតាឯណោះទេ។ សមាជិកគ្រួសារម្នាក់តោងតែគិតថា

បង្គ្រប់គ្នាទៅវិញទៅមក ក្រឡេកបែរមើលទៅក្រោយ គិតជាថ្មីម្ដងទៀតហើយបង្ហាញគម្រូល្អដល់កុមារនិងយុវជនដែលជាជន្ទល់ជាសរសរទ្រូងនៃប្រទេសជាតិ។

## ន័យពិតប្រាកដនៃការបណ្ដុះបណ្ដាលធនធានមនុស្សគឺចញ្ចឹមកុមារនិងយុវជនឱ្យទៅជាមនុស្សដែលមានមនោសញ្ចេតនានិងសមានចិត្

និយាយអីចឹងដល់ថ្ងៃទី១១ខែមីនានេះនឹងចូលដល់ខួបទី១០ឆ្នាំពេញនៃគ្រោះមហន្តរាយនៅតំបន់ផ្នែកខាងកើតជប៉ុនហើយ។អ្នកដែលភៀសខ្លួនដោយសារមហន្តរាយនេះមានចំនួនលើសពី៤ម៉ឺននាក់។ហើយអ្នកដែលមិនអាចត្រឡប់ទៅស្រុកកំណើតវិញបានដោយសារតែមូលហេតុគ្រោះថ្នាក់ឡបរមាណូ មានច្រើនណាស់។យើងទាំងអស់គ្នាតោងតែដណ្ដឹងសួរខ្លួនឯងជានិច្ចជាកាលថាតើអ្វីទៅដែលសំខាន់បំផុតហើយគិតពីទឹកចិត្តរបស់អ្នករងគ្រោះព្រមទាំងបន្តធ្វើខ្លួនឱ្យទៅជាជន្ទល់ចិត្តរបស់គេផង។

នៅពេលដែលគ្រោះមហន្តរាយកើតឡើងខ្ញុំព្រះករុណាអាត្មាភាពបានទាញឧទាហរណ៍ពីសាស្ត្រាចិនបុរាណដោយនិយាយថា៖នៅពេលដែលយើងធ្វើគម្រោងការមួយឆ្នាំគ្មានអ្វីក្រៅពីដាំគ្រាប់ធញ្ញជាតិទេ បើធ្វើគម្រោងការ១០ឆ្នាំត្រូវដាំដើមឈើហើយបើធ្វើគម្រោងមួយជីវិតត្រូវបណ្ដុះ

មនុស្ស។ហើយដើម្បីបង្កើតសង្គមល្អមួយក្នុងតំបន់គ្មានអ្វីល្អជាងបណ្តុះបណ្តាលមនុស្សទេ។

មិនត្រឹមតែបណ្តុះបណ្តាលប្រាជ្ញា និង វិចារណញ្ញាណទេត្រូវបណ្តុះទាំងមនោសញ្ចេតនាសមានចិត្តថែមទៀត។បើមិនដូច្នោះទេមិនអាចហៅថា

បណ្តុះបណ្តាលមនុស្សក្នុងន័យត្រឹមត្រូវហើយមិនអាចបង្កើតជាសង្គមដែលមានបេះដូងទូលាយបានឡើយ។

ព្រះគ្រូដូហ្គេនលោកបានមានពុទ្ធដីកាថា៖ទោះខ្លួនឯងមិនទាន់ឆ្លងផុតក៏ដោយ ក៏ត្រូវឱ្យអ្នកដទៃឆ្លងទៅមុនដែរ។នៅពេលដែលមានរឿងរសេម

រសាម ហើយមិនដឹងដើរទៅផ្លូវណា ឬកំពុងមានទុក្ខក្តី ប្រសិនបើឃើញអ្នកដទៃគេលំបាកយើងតោងតែមានចិត្តមេត្តាជួយគេ។មិនត្រូវគិតថាឱ្យតែខ្លួនឯងបានសុខអ្នកណាទៅជាយ៉ាងម៉េចក៏ទៅៗនោះទេត្រូវប្រឹងឱ្យអស់ពីកម្លាំងកាយនិងកម្លាំងចិត្តជួយសង្គ្រោះឱ្យមនុស្សគ្រប់គ្នាបានសុខ

សប្បាយ។ហើយលោកបានបង្រៀនថានោះហើយជាចិត្តមេត្តារបស់ព្រះពោធិសត្វ។

ពោលគឺថាដូចពាក្យស្លោករបស់រីហ្សូកូសេកៃយើងដែលលើកឡើងថា 《អ្នកដទៃជាចំបង》នោះគឺយើងតោងតែបណ្តុះបណ្តាលមនុស្សឱ្យមានមានមនោសញ្ចេតនា ជាស្វាមីភរិយា ជាមាតាបិតា ជាជីដូនជីតា និងជាសង្ឃយើងតោងតែពួតដៃគ្នាសាមគ្គីគ្នាជាធ្លុងមួយដោះស្រាយបញ្ហាចំបងនេះ។

ក្នុងមួយឆ្នាំនេះអាត្មាភាពយល់ថាចំណងគ្រួសារ ចំណងសង្ឃនឹងកាន់តែមាំទៅៗយើងជួយគ្នាទៅវិញទៅមកហើយជម្នះលើក្តីលំបាកទាំងឡាយដែលនៅពីមុខយើងឱ្យបាន។

(ដកស្រង់ពី『កាសែតកូសេ』ថ្ងៃ៣ខែមករា ឆ្នាំ២០២១)



# Rissho Kosei-kai: A Global Buddhist Movement




**Rissho Kosei-kai Buddhist Church of Hawaii**
2280 Auhuhu Street, Pearl City, HI 96782, USA
TEL: 1-808-455-3212FAX: 1-808-455-4633
Email: sangha@rkhawaii.org URL: http://www.rkhawaii.org

**Rissho Kosei-kai Maui Dharma Center**
1817 Nani Street, Wailuku, HI 96793, USA
TEL: 1-808-242-6175 FAX: 1-808-244-4625

**Rissho Kosei-kai Kona Dharma Center**
73-4592 Mamalahoa Highway, Kailua-Kona, HI 96740, USA
TEL: 1-808-325-0015 FAX: 1-808-333-5537

**Rissho Kosei-kai Buddhist Center of Los Angeles**
2707 East First Street, Los Angeles, CA 90033, USA
POBox 33636, CA 90033, USA
TEL: 1-323-269-4741 FAX: 1-323-269-4567
Email: rk-la@sbcglobal.net URL: http://www.rkina.org/losangeles.html

Please contact Rissho Kosei-kai Buddhist Center of Los Angeles
**Rissho Kosei-kai Buddhist Center of Arizona**
**Rissho Kosei-kai Buddhist Center of Colorado**
**Rissho Kosei-kai Buddhist Center of San Diego**
**Rissho Kosei-kai Buddhist Center of Las Vegas**
**Rissho Kosei-kai Buddhist Center of Dallas**

**Rissho Kosei-kai of San Francisco**
1031 Valencia Way, Pacifica, CA 94044, USA
POBox 778, Pacifica, CA 94044, USA
TEL: 1-650-359-6951 Email: info@rksf.org URL: http://www.rksf.org

Please contact Rissho Kosei-kai of San Francisco
**Rissho Kosei-kai of Sacramento**
**Rissho Kosei-kai of San Jose**

**Rissho Kosei-kai of New York**
320 East 39th Street, New York, NY 10016, USA
TEL: 1-212-867-5677 Email: rkny39@gmail.com URL: http://rk-ny.org

**Rissho Kosei-kai of Chicago**
1 West Euclid Ave., Mt. Prospect, IL 60056, USA
TEL: 1-773-842-5654
Email: murakami4838@aol.com URL: http://rkchi.org

**Rissho Kosei-kai of Fort Myers**
URL: http://www.rkftmyersbuddhism.org

**Rissho Kosei-kai Dharma Center of Oklahoma**
2745 N.W. 40th St., Oklahoma City, OK 73112, USA
POBox 57138, Oklahoma City, OK 73157, USA
TEL: 1-405-943-5030 FAX: 1-405-943-5303
Email: rkokdc@gmail.com URL: http://www.rkok-dharmacenter.org

**Rissho Kosei-kai Dharma Center of Denver**
1255 Galapago St. #809 Denver, CO 80204, USA
TEL: 1-303-446-0792

**Rissho Kosei-kai Dharma Center of Dayton**
617 Kling Drive, Dayton, OH 45419, USA
URL: http://www.rkina-dayton.com

**The Buddhist Center Rissho Kosei-kai International of North America (RKINA)**
2707 East First St., Suite #1, Los Angeles, CA 90033, USA
TEL: 1-323-262-4430 FAX: 1-323-269-4567
Email: dharmasa@rksabuddhistcenter.org
URL: http://rksabuddhistcenter.org

**Rissho Kosei-kai Buddhist Center of San Antonio**
(Address) 6083 Babcock Road, San Antonio, TX 78240, USA
(Mail) POBox 692148, San Antonio, TX 78249, USA
TEL: 1-210-558-4430 FAX: 1-210-696-7745
Email: dharmasanantonio@gmail.com
URL: http://www.rkina.org/sanantonio.html

**Rissho Kosei-kai of Seattle's Buddhist Learning Center**
28621 Pacific Highway South, Federal Way, WA 98003, USA
TEL: 1-253-945-0024 Email: rkseattlewashington@gmail.com
URL: http://buddhistlearningcenter.org

**Rissho Kosei-kai of Vancouver**
Please contact RKINA

**Risho Kossei-kai do Brasil**
Rua Dr. José Estefno 40, Vila Mariana, São Paulo-SP, CEP 04116-060, Brasil
TEL: 55-11-5549-4446, 55-11-5573-8377
Email: risho@rkk.org.br URL: http://www.rkk.org.br

**Risho Kossei-kai de Mogi das Cruzes**
Av. Ipiranga 1575-Ap 1, Mogi das Cruzes-SP, CEP 08730-000, Brasil

**在家佛教韓国立正佼成会**
〒 04420 大韓民国 SEOUL 特別市龍山區漢南大路 8 路 6-3
6-3, 8 gil Hannamdaero Yongsan gu, Seoul, 04420, Republic of Korea
TEL: 82-2-796-5571 FAX: 82-2-796-1696

**在家佛教韓国立正佼成会釜山支部**
〒 48460 大韓民国釜山廣域市南區水營路 174, 3F
3F, 174 Suyoung ro, Nam gu, Busan, 48460, Republic of Korea
TEL: 82-51-643-5571 FAX: 82-51-643-5572

**社團法人在家佛教立正佼成會**
台湾台北市中正區衡陽路 10 號富群資訊大厦 4 樓
4F, No. 10, Hengyang Road, Jhongjheng District, Taipei City 100, Taiwan
TEL: 886-2-2381-1632, 886-2-2381-1633 FAX: 886-2-2331-3433

**台南市在家佛教立正佼成會**
台湾台南市崇明 23 街 45 號
No. 45, Chongming 23rd Street, East District, Tainan City 701, Taiwan
TEL: 886-6-289-1478 FAX: 886-6-289-1488
Email: koseikaitainan@gmail.com

**Rissho Kosei-kai South Asia Division**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141 FAX: 66-2-716-8218

**Rissho Kosei-kai of Kathmandu**
Ward No. 3, Jhamsikhel, Sanepa-1, Lalitpur, Kathmandu, Nepal

**Rissho Kosei-kai of Kolkata**
E-243 B. P. Township, P. O. Panchasayar, Kolkata 700094, India

**Rissho Kosei-kai of Kolkata North**
AE/D/12 Arjunpur East, Teghoria, Kolkata 700059,
West Bengal, India

**Rissho Kosei-kai of Bodhgaya Dharma Center**
Ambedkar Nagar, West Police Line Road, Rumpur, Gaya-823001,
Bihar, India

**Rissho Kosei-kai of Patna Dharma Center**
Please contact Rissho Kosei-kai of Kolkata

**Rissho Kosei-kai of Central Delhi**
77 Basement D.D.A. Site No. 1, New Rajinder Nagar,
New Delhi 110060, India

**Rissho Kosei-kai of Singapore**
Please contact Rissho Kosei-kai International

**Rissho Kosei-kai of Phnom Penh**
W.C. 73, Toul Sampaov Village, Sangkat Toul Sangke, Khan Reouseykeo,
Phnom Penh, Cambodia

**RKISA Rissho Kosei-kai International of South Asia**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141 FAX: 66-2-716-8218

**Rissho Kosei-kai of Bangkok**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8216 FAX: 66-2-716-8218 Email: info.thairissho@gmail.com

**Rissho Kosei Dhamma Foundation**
No. 628-A, Station Road, Hunupitiya, Wattala, Sri Lanka
TEL: 94-11-2982406 FAX: 94-11-2982405

**Rissho Kosei-kai of Polonnaruwa**
Please contact RiKISA

**Rissho Kosei-kai Bangladesh**
85/A Chanmari Road, Lalkhan Bazar, Chittagong, Bangladesh
TEL/FAX: 880-31-626575

**Rissho Kosei-kai Mayani**
Mayani Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Damdama**
Damdama Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Satbaria**
Village: Satbaria Bepari Para, Chandanaih, Chittagong, Bangladesh

**Rissho Kosei-kai Chendhirpuni,**
Village: Chendhirpuni, P.O.: Adhunogar, P.S.: Lohagara, Chittagong,
Bangladesh

**Rissho Kosei-kai Raozan**
Dakkhin Para, Ramzan Ali Hat, Raozan, Chittagong, Bangladesh

**Rissho Kosei-kai Laksham**
Village: Dhupchor, Laksham, Comilla, Bangladesh

**Rissho Kosei-kai Dhaka**
408/8 DOSH, Road No 7 (West), Baridhara, Dhaka, Bangladesh

**Rissho Kosei-kai Cox's Bazar**
Ume Burmize Market, Tekpara, Sadar, Cox's Bazar, Bangladesh

Please contact Rissho Kosei-kai Bangladesh
**Rissho Kosei-kai Patiya**
**Rissho Kosei-kai Ramu**
**Rissho Kosei-kai Aburkhiln**

**Buddiyskiy khram "Lotos"**
4 Gruzinski Alley, Yuzhno-Sakhalinsk 693005, Russia
TEL: 7-4242-77-05-14

**Rissho Kosei-kai of Hong Kong**
Flat D, 5/F, Kiu Hing Mansion, 14 King's Road, North Point, Hong Kong, China

**Rissho Kosei-kai Friends in Shanghai**

**Rissho Kosei-kai of Ulaanbaatar**
(Address) 15F Express Tower, Peace avenue, khoroo-1, Chingeltei district,
Ulaanbaatar 15160, Mongolia
(Mail) POBox 1364, Ulaanbaatar-15160, Mongolia
TEL: 976-70006960 Email: rkkmongolia@yahoo.co.jp

**Rissho Kosei-kai of Erdenet**
Please contact Rissho Kosei-kai International

**Rissho Kosei-kai di Roma**
Via Torino, 29, 00184 Roma, Italia
TEL/FAX: 39-06-48913949 Email: roma@rk-euro.org

Please contact Rissho Kosei-kai di Rome
**Rissho Kosei-kai of Paris**
**Rissho Kosei-kai of Venezia**

**Rissho Kosei-kai of the UK**
29 Ashbourne Road, London W5 3ED, UK
TEL: 44-20-8933-3247 Email: info@rkuk.org URL: https://www.rkuk.org
Facebook: https://www.facebook.com/RKUnitedKingdom
Twitter: https://twitter.com/rkuk_official
Instagram: https://www.instagram.com/rkuk_official

**Rissho Kosei-kai International Buddhist Congregation (IBC )**
166-8537 東京都杉並区和田 2-7-1 普門メディアセンター 3F
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan
TEL: 03-5341-1230 FAX: 03-5341-1224 URL: http://www.ibc-rk.org

**Published by Rissho Kosei-kai International**